ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**អត្ថបទស្រាវជ្រាវ**

# តួនាទីរបស់មេធាវី នៅក្នុង រឿងក្តីរដ្ឋប្បវេណី

share by **បណ្ណាល័យច្បាប់**-Law Library

lawlibrarysite.wordpress.com

# មាតិកា

១. ជនដែលត្រូវបានមេធាវីតំណាងដោយអាណត្តិក្នុងរឿងក្តីរដ្ឋប្បវេណី: ..... ២
ក-ដើមចោទ ..... ៤
ខ-ចុងចម្លើយ ..... ៤
គ-អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ..... ៥
២. តួនាទីរបស់មេធាវីក្នុងនីតិវិធីរដ្ឋប្បវេណី ..... ៥
២.១ ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ..... ៦
២.១.១-ការរៀបចំ និងការដាក់ឯកសារត្រៀម ..... ៧
២.១.២-ការផ្សះផ្សាដែលធ្វើឡើងដោយមេធាវី ..... ៨
២.១.៣-ការផ្សះផ្សាដោយតុលាការ ..... ៨
២.១.៤-ការអះអាងរបស់គូភាគី ..... ១០
២.១.៦-ការពិនិត្យភស្តុតាងជាឯកសារ ..... ១២
២.២ ដំណើរការនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ..... ១៣
២.២.១-ការសាកល្បងធ្វើការផ្សះផ្សា ..... ១៤
២.២.២-ការធ្វើសេចក្តីថ្លែងការណ៍ ..... ១៤
២.២.៣-ការអះអាងបន្ថែម ឬការដាក់មធ្យោបាយតទល់ ឬការពារថ្មី ..... ១៤
២.២.៤-ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ..... ១៦
២.២.៥-ដំណាក់កាលក្រោយនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ..... ១៦
២.៣-ការទទួលខុសត្រូវរបស់មេធាវី ..... ១៩
២.៣.១-ភក្តីភាពរបស់មេធាវីក្នុងការបំពេញបេសកកម្មជូនអតិថិជន ..... ១៩
២.៣.២-ការរក្សាការសម្ងាត់វិជ្ជាជីវៈសំរាប់អតិថិជន ..... ២១
២.៣.៣-កំហុសចំពោះអតិថិជន ..... ២២

# តួនាទីរបស់មេធាវី

ដោយហេតុថា នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីថ្មីនេះ មានលក្ខណៈខុសប្លែកពីក្រមនីតិវិធីរដ្ឋប្បវេណីចាស់ច្រើន យើង សង្កេតឃើញថា មេធាវីដើរតួនាទីកាន់តែសំខាន់ថែមទៀត ក្នុងការជួយការពារផលប្រយោជន៍ជូនអតិថិជនរបស់ខ្លួន នៅក្នុងដំណើរការនីតិវិធីរបស់តុលាការ ។ លក្ខណៈសំខាន់នៃតួនាទីនេះ ត្រូវបានរកឃើញក្នុងចំណោមមូលហេតុសំខាន់ៗនៃបំលាស់ប្តូរតួនាទីរបស់ចៅក្រមជំនុំជម្រះ ភាពឆាប់រហ័សនៃការដោះស្រាយរឿងក្តី ព្រមទាំងលក្ខខណ្ឌ ដែលទាមទារសម្រាប់ការសរសេរពាក្យបណ្តឹងជាដើម ។ល។ បំលាស់ប្តូរចំបងមួយ ដែលសំខាន់នោះ គឺនៅក្នុងនីតិវិធី ចាស់ចៅក្រមជំនុំជម្រះ ជាចៅក្រមសកម្ម មានន័យថា ក្រោយការដាក់ពាក្យបណ្តឹង បើពិនិត្យឃើញថាពាក្យបណ្តឹង ត្រឹមត្រូវហើយនោះ តុលាការស្វែងរកភស្តុតាងមកបញ្ជាក់អង្គហេតុដោយខ្លួនឯង ចំណែកក្នុងនីតិវិធីថ្មីវិញ តុលាការក្លាយ

ទៅជាអកម្ម បានន័យថា តុលាការមិនធ្វើការស្វែងរកភស្តុតាងទេជាគោលការណ៍ ។ តុលាការដើរតួនាទីត្រឹមតែ ជាអ្នកសម្រេចសេចក្តីតែប៉ុណ្ណោះ។

ក្នុងរឿងរដ្ឋប្បវេណី មេធាវីមានសិទ្ធិពិសេសជាងរឿងក្តីព្រហ្មទណ្ឌ ដោយហេតុថាមេធាវីមានសិទ្ធិធ្វើជាតំណាងដោយអាណត្តិឱ្យកូនក្តីរបស់ខ្លួន តាមរយៈលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ហើយមានសិទ្ធិចាត់ចែងរឿងក្តីនេះបានដោយសេរី ដោយពុំចាំបាច់មានវត្តមានកូនក្តីរបស់ខ្លួនឡើយ លើកលែងតែរឿងក្តីលែងលះ ។ ជាធម្មតា ភាគីអាចធ្វើ

រាល់សកម្មភាព ដែលទាក់ទងនឹងបណ្តឹងដោយខ្លួនឯងផ្ទាល់ ប៉ុន្តែភាគីអាចជ្រើសតាំងអ្នកតំណាងដោយអាណត្តិ ដើម្បីបំពេញការងារនេះជំនួសខ្លួនឯងបាន ។ មេធាវីតំណាងដោយអាណត្តិ អាចដើរតួនាទីជំនួសកូនក្តីខ្លួននៅចំពោះមុខតុលាការ ហើយខ្លួនធ្វើការក្នុងនាមជាភាគីម្ខាងនៃរឿងក្តី ដែលអាចធ្វើអ្វីៗដើម្បីប្រយោជន៍ដល់កូនក្តីរបស់ខ្លួន លើកលែងតែមាន ការជំទាស់ពីកូនក្តីរបស់ខ្លួន ឬសិទ្ធិនេះត្រូវបានកំហិតដោយច្បាប់ប៉ុណ្ណោះ ។ មេធាវីត្រូវចាត់ទុករឿងក្តីរបស់អតិថិជន ដូចជា រឿងរបស់ខ្លួនផ្ទាល់ និងជាពិសេសគិតគូដល់ប្រយោជន៍របស់អតិថិជន ឱ្យដូចជាផលប្រយោជន៍របស់ខ្លួនផងដែរ។

បញ្ញត្តិស្តីពីការតំណាងដោយអាណត្តិរបស់មេធាវី មានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីត្រង់ជំពូកទី ៣ ផ្នែកទី ៤ ស្តីពីអ្នកតំណាងដោយអាណត្តិ និងអ្នកជំនួយ នឹងត្រូវបកស្រាយបង្ហាញជូនខាងក្រោម ត្រង់ចំណុចស្តីពីជន ដែលត្រូវបានមេធាវីធ្វើជាតំណាងដោយអាណត្តិក្នុងរឿងក្តីរដ្ឋបវេណី និងចំណុចស្តីពីមេធាវីក្នុងនីតិវិធីរឿងរដ្ឋប្បវេណី ។

## ១. ជនដែលត្រូវបានមេធាវីតំណាងដោយអាណត្តិក្នុងរឿងក្តីរដ្ឋប្បវេណី:[1]

មុនចូលប្រកបវិជ្ជាជីវៈមេធាវី មេធាវីគ្រប់រូបត្រូវតែទទួល ការបណ្តុះបណ្តាលយ៉ាងហោចណាស់អំពីច្បាប់លក្ខន្តិកៈមេធាវី បទបញ្ជាផ្ទៃក្នុង និងក្រមសីលធម៌មេធាវី ព្រមទាំងបច្ចេកទេសការពារក្តី។ ដូច្នេះ មេធាវីមានកាតព្វកិច្ចប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈ និងការទទួលខុសត្រូវចំពោះកូនក្តីរបស់ខ្លួន។

មេធាវីក៏ត្រូវមានសីលធម៌ខ្ពស់ក្នុងការងារ ដោយធ្វើយ៉ាងណា ឱ្យអតិថិជនរបស់ខ្លួនមានការពេញចិត្ត និងជឿ ជាក់មកលើខ្លួន។ វិជ្ជាជីវៈមេធាវី ជាវិជ្ជាជីវៈមួយរួមចំណែកបម្រើវិស័យយុត្តិធម៌តាមផ្លូវច្បាប់ ដោយគ្មានការរើសអើង លើពូជសាសន៍ ពណ៌សម្បុរ ភេទ ឋានៈ ឡើយ។

មេធាវីមិនអាចធានាមុនចំពោះកូនក្តីរបស់ខ្លួនអំពីលទ្ធផលឈ្នះ ទៅលើរឿងក្តីណាមួយឡើយ ដោយហេតុថា កាតព្វកិច្ចរបស់មេធាវី មិនមែនជាកាតព្វកិច្ចខាងលទ្ធផលនោទេះ ប៉ុន្តែវាជាកាតព្វកិច្ចមធ្យោបាយ ដែលមេធាវី ត្រូវរិះរកមធ្យោបាយសមស្របតាមផ្លូវច្បាប់ ដើម្បីការពារផលប្រយោជន៍ឱ្យកូនក្តីរបស់ខ្លួន ឬនិយាយយ៉ាងខ្លីថា មេធាវី ជាម្ចាស់នៃមធ្យោបាយការពារអតិថិជនរបស់ខ្លួន។

មេធាវី ត្រូវប្រកាន់ឱ្យបានខ្ជាប់ខ្ជួនជាដាច់ខាតនូវអាថ៌កំបាំងវិជ្ជាជីវៈ។ ការសម្ងាត់នេះ មិនអាចត្រូវឱ្យជនណា មួយអាចដកស្រង់យកបានឡើយ ដើម្បីជៀសវាងនូវការធ្លាយចេញអាថ៌កំបាំងទាំងឡាយរបស់អតិថិជន ឬកូនក្តីរបស់ ខ្លួន ដែលនាំឱ្យបាត់បងផលប្រយោជន៍របស់ពួកគេ ។ ត្រូវទុកជាការសម្ងាត់វិជ្ជាជីវៈ គឺរាល់ការពិគ្រោះយោបល់ និងការ ផ្តល់យោបល់លើឯកសារផ្លូវការទាំងឡាយ ដែលមេធាវីតាក់តែង ឡើងសម្រាប់អតិថិជនរបស់ខ្លួន លិខិតស្នាមទាំង ឡាយដែលមេធាវី

[1] មាត្រា ៥៣ -៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

និងអតិថិជនធ្វើការទាក់ទងគ្នា ។ ការរក្សាការសម្ងាត់នេះ វាមានន័យថា ពេលមេធាវីទទួលពិគ្រោះច្បាប់ ឬការពារក្តី ឬតំណាងឱ្យអតិថិជនណាម្នាក់ ហើយគឺមិនអាចនិយាយ ឬទម្លាយរឿងហេតុ ដែលខ្លួនបានដឹងទៅ ជនណាម្នាក់ ឬច្រើននាក់បានដឹងឡើយ លើកលែងតែមានការអនុញ្ញាតជាមុន ពីកូនក្តីរបស់ខ្លួន (មាត្រា ៥៨ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី)។

មេធាវីមិនត្រូវលាក់លៀមនឹងកូនក្តីនូវអ្វីដែលខ្លួនយល់ថា គួរប្រាប់ដល់កូនក្តី ដើម្បីជាផលប្រយោជន៍ស្រប ច្បាប់របស់កូនក្តី ហើយមេធាវីមិនត្រូវប្រើល្បិចកេងបន្លំទាញយកផលប្រយោជន៍ពីអតិថិជននោះទេ គឺត្រូវប្រកាន់នូវ អត្តចរិតថ្លៃថ្នូរ មានសតិសម្បជញ្ញៈ ទទួលខុសត្រូវទៀងទាត់ មនុស្សធម៌ ឯករាជ្យ និងគោរពច្បាប់។

រវាងមេធាវី និងកូនក្តីបានចងកាតព្វកិច្ចចំពោះគ្នាទៅវិញទៅមក ដោយសារតែកិច្ចសន្យាផ្តល់សេវាកម្មច្បាប់ ហើយដើម្បីបំពេញការងារនេះ មេធាវីត្រូវមានលិខិតពឹងពាក់ពីកូនក្តី ឬលិខិតប្រគល់សិទ្ធិជាអ្នកតំណាងដោយអាណត្តិ ដែលលិខិនេះត្រូវទទួលបានដោយផ្ទាល់ពីកូនក្តី។ ប្រសិនបើជាមេធាវីទទួលបាននូវការពឹងពាក់ពីជនទាំងនោះ ឱ្យធ្វើការ ជាអ្នកតំណាងដោយអាណត្តិ ហើយមេធាវីត្រូវបំពេញភារកិច្ច ក្នុងការតំណាងដោយអាណត្តិឱ្យបានល្អប្រសើរ ហើយ ការសម្រេចចិត្តទាំងឡាយដែលទាក់ទងផលប្រយោជន៍ក្នុងរឿងក្តី ត្រូវមានការយល់ព្រមពីកូនក្តីរបស់ខ្លួនជាមុន។ គួរ កត់សម្គាល់ថា ភាគីអាចជ្រើសតាំងអ្នកតំណាងដោយអាណត្តិបាន តែការជ្រើសតាំងនេះ មិនមែនជាកាតព្វកិច្ចតម្រូវ ចំពោះភាគីទេ ហើយភាគីក៏អាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងក៏បាន។ ទោះបីជាភាគីបានជ្រើសតាំងអ្នកតំណាង អាណត្តិហើយក៏ដោយ ក៏ភាគីនេះអាចចូលរួមនៅក្នុងតុលាការ និងឆ្លើយទាញហេតុផលដោយខ្លួនឯងបានដែរ។ សកម្ម ភាពបណ្តឹង ដែលអ្នកតំណាងដោយអាណត្តិបានធ្វើ ត្រូវបង្កើតអនុភាពដូចគ្នាជាមួយសកម្មភាពបណ្តឹងភាគីបានធ្វើ ដោយផ្ទាល់ខ្លួន។

មេធាវីអាចការពារគ្រប់ជនទាំងឡាយណា ដែលមកពឹងពាក់ខ្លួនតាមការព្រមព្រៀងគ្នាទៅវិញទៅមក រវាង មេធាវី និងអតិថិជននោះ។ ប៉ុន្តែ មេធាវីមានសេរីភាពក្នុងការទទួល ឬមិនទទួលជួយកូនក្តីបើខ្លួនយល់ឃើញថា មានការ ប៉ះពាល់ដល់សតិសម្បជញ្ញៈរបស់ខ្លួន ។

ដូច្នេះហើយ ទើបយើងឃើញថា វិជ្ជាជីវៈមេធាវីអាចធ្វើជាអ្នកតំណាងដោយអាណត្តិ និងការពារក្ដីចំពោះមុខ ច្បាប់តាមការពឹងពាក់ពីជនមួយចំនួនដូចជា ៖

### ក-ដើមចោទ[2]

ដើមចោទ គឺជាបុគ្គលទាំងឡាយ ដែលមានសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ហើយត្រូវបានបុគ្គលម្នាក់ទៀតបំពាបំពានសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ដែលនាំឱ្យមានវិវាទនឹងគ្នា។

ដើមចោទ គឺជាបុគ្គលដែលដាក់ពាក្យបណ្ដឹងមុនគេមកសាលាដំបូង ដើម្បីទាមទារឱ្យតុលាការចេញសាលក្រម កំណត់អំពីសំណងខូចខាត ដែលបង្កឡើងដោយភាគីម្ខាងទៀត ឬអំពីអត្ថិភាព ឬនត្ថិភាពនៃសិទ្ធិ ដែលធ្វើឱ្យខ្លួនបាត់បង់ ខូចខាតផលប្រយោជន៍របស់ខ្លួន។

គួរកត់សម្គាល់ថា ពាក្យដើមចោទ ដើមបណ្ដឹងឧទ្ធរណ៍ និងដើមបណ្ដឹងសាទុក្ខ មានន័យប្រហាក់ប្រហែលគ្នា ដោយគ្រាន់តែពាក្យនីមួយៗ ត្រូវបានប្រើប្រាស់ទៅតាមកំរិតនៃសាលាជំនុំជម្រះក្ដីប៉ុណ្ណោះ ដូចជា ពាក្យដើមចោទត្រូវ បានប្រើប្រាស់ជាទូទៅ សម្រាប់ការជំនុំជម្រះក្ដីលើកទី ១ នៅសាលាដំបូង ហើយដើមបណ្ដឹងឧទ្ធរណ៍ ត្រូវបានប្រើប្រាស់ ការជម្រះក្ដីនៅសាលាឧទ្ធរណ៍ និងដើមបណ្ដឹងសាទុក្ខ ត្រូវបានប្រើប្រាស់ក្នុងការជម្រះក្ដីនៅតុលាការកំពូល ។ មេធាវី អាចធ្វើជាអ្នកតំណាងដោយអាណត្តិ ឱ្យអ្នកទាំងនោះបាននូវគ្រប់ដំណាក់កាលនីតិវិធី។

### ខ-ចុងចម្លើយ[3]

ចុងចម្លើយ គឺជាបុគ្គលដែលត្រូវការពារទៅនឹងការប្ដឹងទាមទាររបស់ដើមចោទ។ ចុងចម្លើយអាចត្រូវចាត់ ទុកថា ជាបុគ្គលដែលបានបំពាបំពានដល់សិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់ដើមចោទ ប៉ុន្តែ ពុំមានន័យថា ចុងចម្លើយសុទ្ធតែបំពាបំពានទាំងអស់នោះទេ ។ ដូច្នេះហើយ នៅពេលដែលដើមចោទបានដាក់ពាក្យបណ្ដឹងប្ដឹងពីចុងចម្លើយ ចុងចម្លើយអាចចូលឆ្លើយបំភ្លឺ និងឆ្លើយដោះសាររាល់ការ

[2] មាត្រា ៣២និង ៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[3] មាត្រា ៣២ និង ៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ទាមទាររបស់ដើមចោទមកលើខ្លួន នៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់ ឬចុងចម្លើយអាចធ្វើការពឹងពាក់ដោយផ្ទេរសិទ្ធិឱ្យមេធាវី ដែលជាតំណាងដោយអាណត្តិ ដើម្បីការពារផលប្រយោជន៍របស់ខ្លួនបានតាមផ្លូវច្បាប់។

### គ-អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី

អ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី គឺជាជនទាំងឡាយណា ដែលត្រូវទទួលបន្ទុកសងរាល់ការខូចខាតទាំងផ្លូវ កាយ និងផ្លូវចិត្ត ដល់អ្នកដែលទទួលរងនូវព្យសនកម្ម ហើយជាជនដែលច្បាប់បានកំណត់ថា ជាអ្នកបំពានកេងប្រវ័ញ្ច ទៅលើបុគ្គលមួយផ្សេងទៀត។ *ជាឧទាហរណ៍* កាលណាមានបញ្ហាកើតឡើង ដែលបណ្តាលមកពីអនីតិជន ភាគច្រើនមានឪពុកម្តាយ ឬសាច់ ញាតិ ជាអ្នកទទួលខុសត្រូវក្នុងរឿងក្តីរដ្ឋប្បវេណី ដែលមានតួនាទីទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណី ជំនួសឱ្យអនីតិ ជននោះ ដោយសារអនីតិជននោះស្ថិតក្រោមអំណាចមេបារបស់ខ្លួន។

ដូច្នេះមេធាវីយល់ព្រមទទួលការការពារឱ្យដើមចោទ ចុងចម្លើយនិងអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី មេធាវីត្រូវតែមានភាពស្មោះត្រង់ចំពោះកូនក្តី រីឯកូនក្តីត្រូវតែមានការជឿជាក់និងភាពស្មោះត្រង់ចំពោះមេធាវីវិញដែរ។ម៉្យាងទៀត មេធាវីត្រូវស្វះស្វែងផ្តល់ព័ត៌មានរួមទាំងភស្តុតាង ដើម្បីជូនសំអាងទៅតុលាការ និងប្រាប់រាល់សេចក្តីសំរេចនៃសាលក្រម។

## ២. តួនាទីរបស់មេធាវីក្នុងនីតិវិធីរដ្ឋប្បវេណី[4]

ទោះបីជាក្នុងរឿងរដ្ឋប្បវេណី ឬរឿងព្រហ្មទណ្ឌ តុលាការនៅតែជាស្ថាប័ន ដែលមានសមត្ថកិច្ចក្នុងនីតិវិធីដោះ ស្រាយរឿងវិវាទទាំងអស់ ដែលបានកើតឡើង ទោះបីជាវិវាទនោះពាក់ព័ន្ធដោយផ្ទាល់ទៅនឹងរឿងឯកជនសុទ្ធសាធក៏ ដោយ ។ ក្នុងរឿងក្តីរដ្ឋប្បវេណី តុលាការជាស្ថាប័នមានសមត្ថកិច្ចសម្រាប់ភាគីចាប់ផ្តើមនីតិវិធីនៃបណ្តឹង ដែល តុលាការ ត្រូវចាត់ ការចាប់តាំងពីពេលទទួលពាក្យបណ្តឹង រហូតដល់ការសម្រេចសេចក្តីជាស្ថាពរ ។ មុនពេលចប់ នីតិវិធីនៃពាក្យបណ្តឹង ភាគីអាចរកមេធាវី ដើម្បីធ្វើការពិគ្រោះយោបល់ច្បាប់ អំពីលទ្ធភាពដោះស្រាយតាមផ្លូវច្បាប់ ឬ ផ្តើមចរចាជាមួយ

[4] មាត្រា ១០៣...១១៣...នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ភាគីម្ខាងទៀតជាមុនសិនបាន ហើយប្រសិនបើយល់ឃើញថា រឿងនោះមិនអាចដោះស្រាយតាម ការព្រមព្រៀងបាននោះទេ ភាគី ឬមេធាវីរបស់ខ្លួន អាចធ្វើពាក្យបណ្ដឹងដាក់ជូនទៅតុលាការ ដើម្បីសុំឱ្យតុលាកាចេញ សាលក្រម តាមការទាមទាររបស់ខ្លួន។ ដូច្នេះ នៅមុនដំណាក់កាលចាប់ផ្ដើមនីតិវិធីនៃបណ្ដឹង មេធាវីនៅតែជាមនុស្ស ដ៏សំខាន់ម្នាក់ សម្រាប់ជួយការពារផលប្រយោជន៍កូនក្ដី និងជួយការពារផលប្រយោជន៍របស់កូនក្ដី ។ នៅក្នុងនីតិវិធីតុលាការវិញ មេធាវីជាអ្នកជួយជម្រុញដល់ដំណើរការកាត់សេចក្ដីឱ្យមានភាពត្រឹមត្រូវ យុត្តិធម៌ និងសមធម៌ ដែលផ្ដល់ឱ្យគូក្ដី អាចទទួលយកបាន។ មេធាវី ជាមនុស្សដែលមានប្រាជ្ញាវាងវៃ និងមានចំណេះដឹងខ្ពស់ខាងផ្នែកច្បាប់ ដូច្នេះ វត្តមានរបស់មេធាវីនៅអមជាមួយភាគី ឬកូនក្ដីនៅពេលមានវិវាទ អាចជួយការពារផលប្រយោជន៍ឱ្យកូនក្ដីបាន និងធ្វើឱ្យនីតិវិធីបណ្ដឹង និងការដោះស្រាយរឿងក្ដីនៅតុលាការ កាន់តែមានភាពយុត្តិធម៌ និងឆាប់រហ័ស។

ដើម្បីអនុវត្តភារកិច្ចខាងលើឱ្យបានត្រឹមត្រូវ និងសមស្របទៅតាមច្បាប់ជាធរមាន មេធាវីដែលការពារ ឬ តំណាងដោយអាណត្តិឱ្យកូនក្ដីរបស់ខ្លួន សម្រាប់ការដោះស្រាយវិវាទតុលាការ ត្រូវឆ្លងកាត់និតិវិធីត្រៀមសម្រាប់ការ ទាញហេតុផល និងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដែលត្រូវអនុវត្តតាមដំណាក់កាលនីមួយៗ ដូចខាងក្រោម ៖

## ២.១ ដំណើរការនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល[5]

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបានធ្វើឡើង បន្ទាប់ពីភាគីដើមចោទបានដាក់ពាក្យបណ្ដឹងរបស់ខ្លួនមកតុលាការ ។ នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល គឺជាដំណាក់កាលដើមមួយ ដែលធ្វើឡើងដោយតុលាការ ដើម្បី រៀបចំសេចក្ដីអះអាងរបស់ភាគី និងបំភ្លឺនូវចំណុចវិវាទនៃរឿងក្ដី។ នីតិវិធីនេះ ធ្វើឡើងដើម្បីកាត់បន្ថយនូវចំណុចវិវាទ ឬ កុំឱ្យមានភាពស្មុគស្មាញលើចំនុចវិវាទ ដែលអាចជួយសម្រួលដល់ចៅក្រមក្នុងការវិនិច្ឆ័យរឿងក្ដី ដែលត្រូវជំនុំជម្រះ នៅក្នុងនីតិវិធីទាញយកហេតុផលដោយផ្ទាល់មាត់។ វាជានីតិវិធីមួយដែលតុលាការ ត្រូវធ្វើការពិគ្រោះយោបល់ជាមួយគូភាគីមុនសិន ដើម្បីរៀបចំសេចក្ដីអះអាងរបស់ភាគី និងបំភ្លឺនូវចំនុចវិវាទ។

[5] មាត្រា ១០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ក្រមនីតិវិធីរដ្ឋប្បវេណី ពុំបានកំណត់ថា តើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល អាចធ្វើឡើងប៉ុន្មានដង នោះទេ តុលាការត្រូវកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះ ក្នុងកំឡុងពេល ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្តឹងត្រូវបានដាក់ ហើយត្រូវធ្វើឡើងនៅកាលបរិច្ឆេទដែលគូភាគីអាចចូលរួមបាន ។

នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបានបែងចែកជាដំណាក់កាលផ្សេងៗ ដូចជា ការសាកល្បង ផ្សះផ្សា ការអះអាងរបស់គូភាគី សិទ្ធិបំភ្លឺតុលាការ និងការពិនិត្យភស្តុតាងជាឯកសារ ដែលដំណាក់កាលនីមួយៗនេះ សុទ្ធតែអាចតំណាងដោយមេធាវី ដើម្បីការពារផលប្រយោជន៍កូនក្តី លើកលែងតែករណីលែងលះ។

## ២.១.១-ការរៀបចំ និងការដាក់ឯកសារត្រៀម [6]

នៅក្នុងដំណាក់កាលដំបូង នៃនីតិវិធីត្រៀមសម្រាប់ការទាញយកហេតុផល តុលាការអាចបង្គាប់អោយភាគី ដាក់ឯកសារត្រៀមបាន។ *ឯកសារត្រៀម គឺជាឯកសារដែលភាគីនីមួយៗដាក់ជូនទៅតុលាការ និងភាគីម្ខាងទៀតក្នុង គោលបំណងជូនដំណឹងអំពីចំណុច ដែលខ្លួននឹងធ្វើសេចក្តីថ្លែងការណ៍នៅកាលបរិច្ឆេទបន្ទាប់* ។ ឯកសារត្រៀមនេះ ត្រូវ មានសរសេរអំពីមធ្យោបាយតទល់ ឬការពារខ្លួន និងសេចក្តីថ្លែងការណ៍ចំពោះមធ្យោបាយតទល់ ឬការពារខ្លួនរបស់ ភាគីទៀត ។ មធ្យោបាយតទល់ ត្រូវធ្វើឡើងដោយដើមចោទ ចំណែកមធ្យោបាយការពារខ្លួន ត្រូវធ្វើឡើងដោយចុង ចម្លើយ ។ ជាញឹកញាប់វាត្រូវបានធ្វើឡើងដោយមេធាវីតំណាងដោយអណត្តិអោយគូភាគី ។ មធ្យោបាយតទល់ គឺជា ការសរសេរនៅក្នុងពាក្យបណ្តឹងនូវចំណុចចាំបាច់នានា ស្របទៅតាមបញ្ញត្តិមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី អង្គ

ហេតុដែលជាមូលហេតុនៃការទាមទារ ព្រមទាំង អង្គហេតុសំខាន់ៗដែលទាមទារឱ្យមានការបញ្ជាក់ភស្តុតាង។ ចំណែកមធ្យោបាយការពារខ្លួន ដែលចុងចម្លើយដាក់ទៅតុលាការ ត្រូវសរសេរអំពីការឆ្លើយតបចំពោះខ្លឹមសារនៃសាលក្រម ដែលដើមចោទទាមទារឱ្យតុលាការចេញ ការទទួលស្គាល់ ឬមិន

[6] មាត្រា ១០១នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ទទួលស្គាល់នូវអង្គហេតុ ដែលមានក្នុងពាក្យបណ្តឹងរបស់ដើមចោទ និង អង្គហេតុតវ៉ាផ្សេងៗជាអាទ៍ ។ ឯកសារត្រៀម ត្រូវដាក់ជូនតុលាការទៅតាមអំឡុង ពេលដែលតុលាការបានកំណត់ ដែលមេធាវីជាអ្នកទទួលខុសត្រូវក្នុងការរៀបចំឯកសារទាំងនេះ ដែលជាមធ្យោបាយការពារខ្លួន។

### ២.១.២-ការផ្សះផ្សាដែលធ្វើឡើងដោយមេធាវី [7]

ក្នុងនាមជាអ្នកតំណាងដោយអាណត្តិ មេធាវីអាចចូលរួមសាកល្បង ធ្វើការផ្សះផ្សាជាមួយភាគីម្ខាងទៀត បាន ប្រសិនបើមានការព្រមព្រៀងពីកូនក្តីរបស់ខ្លួន។ មេធាវីក៏អាចដើរតួនាទី ជាអ្នកធ្វើការផ្សះផ្សាផងដែរ ដែលអាចធ្វើ ជាអ្នកសំរុះសម្រួល ពន្យល់ណែនាំដល់កូនក្តី ព្រមទាំងបង្ហាញនូវលទ្ធផលល្អ មិនល្អ និងការខាតបង់នានា ដែលអាចកើត

មានឡើង ប្រសិនបើរឿងក្តីនេះ នៅតែបន្តដោះស្រាយតាមនីតិវិធីរបស់តុលាការ។ ដើម្បីធ្វើការងារនេះ មេធាវីត្រូវ មានភារកិច្ចសិក្សាសំណុំរឿងឱ្យបានច្បាស់លាស់ និងល្អិតល្អន់ ហើយត្រូវប្រឹងប្រែងស្វែងរកភស្តុតាង និងសាក្សីសម្រាប់ធ្វើការបំភ្លឺនូវចំណុចវិវាទ និងការអះអាងទាំងឡាយរបស់ខ្លួន ។ មេធាវីអាចធ្វើការណាត់ជួបភាគី ម្ខាងទៀត ឬរៀបចំ ការជួបគ្នារវាងភាគីទាំងពីរ ដើម្បីជជែកពិភាក្សារកដំណោះស្រាយសមស្របណាមួយ ដែលគូភាគីអាចទទួលយកបាន។

ក្នុងករណីដែលការផ្សះផ្សារបស់មេធាវី ធ្វើមិនទទួលបានផលជាវិជ្ជមានទេ នោះការផ្សះផ្សា នឹងត្រូវធ្លាក់ទៅ លើតុលាការវិញ ហើយត្រូវធ្វើទៅតាមគោលការណ៍ចំពោះមុខនៃបណ្តឹងក្នុងរឿងរដ្ឋប្បវេណី។

### ២.១.៣-ការផ្សះផ្សាដោយតុលាការ [8]

ការផ្សះផ្សាដោយតុលាការ មិនត្រឹមតែធ្វើឡើងនៅក្នុងដំណាក់កាល នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុ ផលប៉ុណ្ណោះទេ គឺតុលាការអាចធ្វើការផ្សះផ្សា នៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធី។ នៅក្នុងដំណាក់កាលនេះ តុលាការអាចធ្វើការផ្សះផ្សាគូភាគី ដោយមិនមានវត្តមានរបស់មេធាវី។

---

[7] មាត្រា ៣ នៃច្បាប់ស្តីពីលក្ខន្តិកៈមេធាវី-មាត្រា៣០ និង៣១ នៃ ក្រមសីលធម៌វិជ្ជាជីវៈមេធាវី

[8] មាត្រា ៩៧ -១០៤ និង២២០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ជាគោលការណ៍ ការផ្សះផ្សាត្រូវធ្វើឡើង ដោយមានវត្តមានរបស់គូភាគី ហើយត្រូវមានឆន្ទៈព្រមព្រៀងរបស់គូភាគី និងអ្នកមានផលប្រយោជន៍ទាក់ទិននឹង រឿងក្តីនោះ ជាអ្នកសម្រេចដោយខ្លួនឯង ប៉ុន្តែមេធាវីតំណាងដោយអាណត្តិអាចចូលរួមធ្វើនីតិវិធីផ្សះផ្សានេះបាន ដោយ អនុវត្តទៅតាមទំហំនៃការចង់បានរបស់កូនក្តីរបស់ខ្លួន លើកលែងតែរឿងក្តីលែងលះដែលច្បាប់មិនអនុញ្ញាត។ ការផ្សះ ផ្សាដែលឈានទៅរកការព្រមព្រៀងគ្នា ភាគច្រើនជាការផ្សះផ្សា ដែលគូភាគីមានវត្តមាននៅពេលនោះ ហើយមេធាវី គ្រាន់តែចូលរួមជួយផ្តល់យោបល់បន្ថែម ទៅលើការផ្សះផ្សា និងការពារផលប្រយោជន៍កូនក្តីរបស់ខ្លួន។

នៅក្នុងដំណាក់កាលនេះ ប្រសិនបើភាគីមានការសះជានឹងគ្នា ឬលះបង់នូវការទាមទារ ឬទទួលស្គាល់នូវការ ទាមទារ នោះតុលាការត្រូវកត់ត្រាទុកនៅក្នុងកំណត់ហេតុ ហើយកំណត់ហេតុនេះ មានអានុភាពដូចគ្នានឹងសាលក្រម ស្ថាពរដែរ[9]។

ក្នុងរឿងលែងលះ មេធាវីមិនអាចធ្វើការតំណាងបានទេ ដោយសារវាគឺជាមនោសញ្ចេតនាផ្ទាល់រវាងប្តី និង ប្រពន្ធ ការសម្រេចអំពីជោគវាសនា និងអនាគតរបស់កូន ប៉ុន្តែមេធាវីអាចចូលរួមស្តាប់នៅក្នុងដំណាក់កាលផ្សះផ្សា បាននៅក្នុងរឿងក្តីប្រភេទនេះ។ មេធាវីអាចការពារកូនក្តីរបស់ខ្លួនទាក់ទងនឹងការគ្រប់គ្រងថែរក្សាចាត់ចែង និងបែង ចែកទ្រព្យសម្បត្តិ ព្រមទាំងសិទ្ធិគ្រប់គ្រងលើកូន និងកាតព្វកិច្ចបង់អាហារកិច្ច ប្រសិនបើមាន។

ករណីដែលមេធាវីទទួលបានសិទ្ធិត្រឹមតែធ្វើការការពារ មេធាវីត្រូវធ្វើយ៉ាងណា ឃ្លាំមើលពីការចាត់ការនីតិវិធី របស់តុលាការ ថាតើការចាត់ការរឿងក្តីធ្វើឡើងត្រឹមត្រូវតាមនីតិវិធី និងទាន់ពេលវេលាដែរឬទេ ករណីដែលតុលាការ មិនបានកោះហៅគូភាគីមកផ្សះផ្សាទេ ដូច្នេះ មេធាវីអាចស្នើសុំឱ្យតុលាការចាត់ការតាមនីតិវិធីភ្លាម ព្រោះការពន្យារ ពេល ជាហេតុធ្វើមានការខាតបង់ផលប្រយោជន៍កូនក្តី ទាំងពេលវេលា ទាំងប្រាក់កាស។

---

[9] មាត្រា ២២២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ប្រសិនបើការផ្សះផ្សានេះបានសម្រេច តុលាការត្រូវធ្វើការកត់ត្រានៅក្នុងកំណត់ហេតុ ដែលកំណត់ហេតុនេះ មានអានុភាពដូចគ្នានឹងសាលក្រមស្ថាពរដែរ ប្រសិនបើមិនអនុវត្តតាម ភាគីអាចសុំទៅតុលាការអនុវត្ត។

ប៉ុន្តែ បើការផ្សះផ្សាមិនទទួលបាននូវលទ្ធផលសះជានឹងគ្នាវិញ អ្វីដែលមេធាវីត្រូវធ្វើបន្ទាប់នោះគឺថាតុលាការ នឹងបង្គាប់ឱ្យមេធាវីទាំងសងខាង ដែលតំណាង និងការពារភាគីជូនសំអាងផ្សេងៗដាក់ជូនតុលាការ ដើម្បីចាត់ការទៅ តាមនីតិវិធីបន្ត។ ការផ្សះផ្សាអាចធ្វើបានផងដែរ នៅក្នុងដំណាក់កាលសវនាការជំនុំជម្រះ ហើយមេធាវីក៏មានសិទ្ធិស្នើ សុំចៅក្រមធ្វើការផ្សះផ្សាជាមុនផងដែរ។

### ២.១.៤-ការអះអាងរបស់គូភាគី [10]

នៅក្នុងដំណាក់កាលនេះ តុលាការត្រូវឱ្យដើមចោទធ្វើសេចក្តីថ្លែងការណ៍ ដោយផ្ទាល់មាត់អំពីសាលក្រមដែល ទាមទារ អំពីអង្គហេតុចាំបាច់ដើម្បីបញ្ជាក់នូវការទាមទារ អំពីអង្គហេតុដែលជាមូលហេតុនៃការទាមទារនិងអង្គហេតុ សំខាន់ៗក្នុងចំណោមអង្គហេតុ ដែលជាមូលហេតុនៃការទាមទារដែលមាននៅក្នុងពាក្យបណ្តឹង ។ បន្ទាប់មកត្រូវឱ្យចុង ចម្លើយធ្វើសេចក្តីថ្លែងការណ៍ដោយផ្ទាល់មាត់តប ចំពោះខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទ។ នេះជា ដំណាក់កាល ដែលតុលាការត្រូវពិនិត្យទៅចំណុចវិវាទរបស់គូភាគី ដែលមាននៅក្នុងមធ្យោបាយតទល់របស់ដើមចោទ និងមធ្យោបាយការពារខ្លួនរបស់ចុងចម្លើយ។ ដូច្នេះ ដំណាក់កាលដាក់មធ្យោបាយតទល់ ឬការពារខ្លួននេះ ក្នុងនីតិវិធី ត្រៀមសម្រាប់ទាញហេតុផល មេធាវីធ្វើការប្រមូលភស្តុតាងសំខាន់ យកព័ត៌មានពីសាក្សីផ្សេងៗ សិក្សាអំពីកម្មវត្ថុ ទំនាស់ វាយតម្លៃ និងបកស្រាយភស្តុតាងទាំងនោះ ឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីយកទៅប្រើនៅក្នុងនីតិវិធីនៃការទាញហេតុផលផ្ទាល់មាត់ ឱ្យប្រព្រឹត្តទៅបានត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់នៃរឿងក្តី និងទាន់ពេលវេលា។

[10] មាត្រា ១០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

មេធាវីមានសិទ្ធិស្នើសុំតុលាការ ក្នុងការពិនិត្យ និងថតចម្លងរាល់សំណុំរឿង ឯកសារដែលពាក់ព័ន្ធទៅនឹងរឿងក្ដី ហើយដើម្បីធានាឱ្យបាននូវផលប្រយោជន៍របស់កូនក្ដីខ្លួន មេធាវីត្រូវសិក្សាសំណុំរឿងរបស់កូនក្ដីឱ្យបានល្អិតល្អន់ និងយល់ឱ្យ

ច្បាស់នូវអត្ថន័យនៃសំណុំរឿង មូលហេតុ និងស្ថានភាព ដែលបង្កឱ្យមានទំនាស់កើតឡើង។ ម៉្យាងទៀតត្រូវ ធ្វើការកត់សំគាល់ថា ភស្តុតាងដែលមាន ឬដែលប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ ដើម្បីធ្វើការស្រាយបំភ្លឺបានត្រឹម ត្រូវអំពីសិទ្ធិ និងកាតព្វកិច្ចស្របច្បាប់របស់កូនក្ដីខ្លួនហើយ ឬនៅ ។

## ២.១.៥-ការបំភ្លឺនូវចំណុចវិវាទ [11]

ជាទូទៅ ចំណុចទាំងឡាយណា ដែលភាគីទាំងសងខាងប្រកែកគ្នាអំពីអង្គហេតុ គេហៅថា ចំណុចវិវាទ។ ជាទូទៅ គឺសំដៅទៅលើអង្គហេតុ ដែលបានលើកឡើងដោយភាគី ហើយត្រូវភាគីម្ខាងទៀតឆ្លើយថា មិនបានដឹង ។

នៅពេលដែលយល់ឃើញថា ការអះអាងរបស់ភាគីមានភាពមិនច្បាស់លាស់ ឬក៏ការបញ្ជាក់ភស្តុតាងមិនគ្រប់ គ្រាន់ ដែលធ្វើឱ្យតុលាការមិនអាចក្ដាប់បាននូវអត្ថន័យ តុលាការអាចសាកសួរភាគី ឬបង្គាប់ឱ្យភាគី (មេធាវី) ធ្វើការ បំភ្លឺអះអាង ឬបញ្ជាក់ភស្តុតាងបាន។ ការប្រើប្រាស់សិទ្ធិបំភ្លឺនេះ គឺដើម្បីឱ្យចំណុចនៃអង្គហេតុដែលទាក់ទងនឹងបណ្ដឹង មានភាពច្បាស់លាស់ ហើយមានសារៈសំខាន់ណាស់ ដែលអនុញ្ញាតអោយតុលាការដឹងបានថា ភាគីទទួលស្គាល់ ឬមិន ទទួលស្គាល់អង្គហេតុដែលបានលើកឡើង។

មេធាវីត្រូវរៀបចំការបំភ្លឺទាំងនេះ ឱ្យបានច្បាស់លាស់ និងគ្រប់ជ្រុងជ្រោយក្នុងអត្ថន័យការពារនូវផលប្រយោ ជន៍កូនក្ដីរបស់ខ្លួន ដាក់ជូនតុលាការពិនិត្យក្នុងអំឡុងពេលដែលបានកំណត់ ។ ប្រសិនបើការឆ្លើយតបនេះ មានការយឺត យ៉ាវ វាអាចធ្វើឱ្យកូនក្ដីរបស់ខ្លួនខូចខាតផលប្រយោជន៍ ។

[11] មាត្រា ១០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

តាមរយៈការរៀបចំការអះអាង និង ការរៀបចំចំណុចវិវាទ ដែលតុលាការបានសួរបញ្ជាក់ទៅគូភាគី ចំណុច វិវាទពិតប្រាកដមួយនឹងត្រូវបានកំណត់ និងទទួលស្គាល់រួមដោយតុលាការ និងភាគីទាំងសងខាង ដែលជាផលប្រយោ ជន៍ដល់ការជម្រះក្តីលើបណ្តឹង។

បន្ទាប់ពីបានកំណត់ចំណុចវិវាទហើយ នៅពេលបញ្ចប់នីតិវិធីនេះ តុលាការបញ្ជាក់ជាមួយភាគីអំពីភស្តុតាង ពាក់ព័ន្ធនឹងចំណុចវិវាទ ដែលត្រូវពិនិត្យក្នុងដំណាក់កាលបន្ទាប់។

### ២.១.៦-ការពិនិត្យភស្តុតាងជាឯកសារ [12]

នៅក្នុងដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ភាគី ឬមេធាវីតំដោយអាណត្តិ អាចស្នើ សុំឱ្យតុលាការធ្វើការពិនិត្យភស្តុតាងបាន។ ការស្នើសុំឱ្យពិនិត្យភស្តុតាងនេះ អាចធ្វើឡើងនៅមុនកាលបរិច្ឆេទនៃនីតិវិធីត្រៀម សម្រាប់ការទាញហេតុផល ឬនៅមុនកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។ ជាគោលការណ៍ ការពិនិត្យភស្តុតាងអាចធ្វើឡើងតាមការស្នើសុំឱ្យពិនិត្យរបស់ភាគី ដែលការស្នើសុំនេះ អាចធ្វើឡើងដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ។ ចំពោះភស្តុតាងដែលអាចទទួលយកមកពិនិត្យបាននៅក្នុងនីតិវិធីនេះ គឺមានតែភស្តុតាងជាឯកសារក្នុងកំរិតចាំបាច់ ដើម្បីរៀបចំចំណុចវិវាទប៉ុណ្ណោះ ដែលយើងហៅថា សេចក្តីបញ្ជាក់ដំបូង[13]។ ចំពោះភស្តុតាងជាសាក្សី ភាគីអាចស្នើសុំដាក់ នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនេះបាន ប៉ុន្តែច្បាប់មិនអនុញ្ញាតឱ្យមាន ការសាកសួរសាក្សីនៅក្នុងដំណាក់កាលនេះឡើយ។ ក្នុងរឿងរដ្ឋប្បវេណី គូភាគីមានភារកិច្ចក្នុងការប្រមូលភស្តុតាង និងរៀបចំដាក់ឯកសារភស្តុតាងនេះ ជូនតុលាការដោយខ្លួនឯង[14]។ ដូច្នេះ មេធាវីត្រូវធ្វើការប្រឹងប្រែងប្រមូលនូវភស្តុតាង ដែលមានប្រយោជន៍ទាំងអស់ទាក់ទងនឹងរឿងក្តីសម្រាប់កូនក្តីរបស់ខ្លួនដាក់ជូនតុលាការ ព្រមទាំង ស្នើសុំឱ្យធ្វើការពិនិត្យភស្តុតាងចាំបាច់ទាំងនេះ។ ព្រោះថា បើមេធាវីប្រមូលបានភស្តុតាង ឬក៏ស្វែងរកសាក្សីបានហើយនោះ ប៉ុន្តែមិនបានស្នើសុំដល់

[12] មាត្រា ១២៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[13] មាត្រា ១៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[14] មាត្រា ១២៣ -១២៤នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

តុលាការអោយធ្វើការពិនិត្យភស្តុតាងទាំងនោះទេ តុលាការជាគោលការណ៍នឹងមិនពិនិត្យភស្តុតាងទាំងនោះទេ នេះគឺជាគោលការណ៍តុលាការអកម្មនៅក្នុងក្រមនីតិវិធីថ្មីនេះ។ ហេតុដូច្នេះ ប្រសិនបើមេធាវីខកខានមិនបានផ្តល់ ឬស្នើសុំដាក់បញ្ចូលភស្តុតាងជូនតុលាការ ឱ្យបានមុននីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបានបញ្ចប់នោះទេភស្តុតាងនេះ មិនអាចប្រើប្រាស់បានឡើយ ដោយសារភាគីមិនអាចដាក់មធ្យោបាយតទល់ ឬការពារខ្លួនជាថ្មីទៀតបានទេនៅក្រោយពេលបញ្ចប់នីតិវិធីនេះ លើកលែងតែ មានករណីពិសេសដូចមានចែងក្នុងមាត្រា ១០៨ ក្រមនីតិវិធីរដ្ឋប្បវេណី។

### ២.២ ដំណើរការនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់[15]

នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ គឺជានីតិវិធីមួយទៀតរបស់តុលាការ បន្ទាប់ពីការបញ្ចប់នីតិវិធីត្រៀម សម្រាប់ការទាញហេតុផល ដែលតុលាការត្រូវកំណត់កាលបរិច្ឆេទ ដើម្បីធ្វើការទាញយកហេតុផលផ្ទាល់មាត់ ព្រមទាំង កោះហៅភាគីមកចូលរួម ។ ការទាញយកហេតុផលដោយផ្ទាល់មាត់ ត្រូវធ្វើឡើងនៅកាលបរិច្ឆេទ ដែលភាគីអាចចូល រួមបាន ហើយត្រូវធ្វើនៅសាលសវនាការជាសាធារណៈ លើកលែងតែ ភាពជាសាធារណៈនេះ អាចបណ្តាលឱ្យខូច សណ្តាប់ធ្នាប់សាធារណៈ ឬដែលមានបញ្ញត្តិពិសេសនៅក្នុងច្បាប់នេះ គឺជាគោលការណ៍ចំពោះមុខភាគី និងគោល ការណ៍សមភាពរវាងគូភាគី[16] ។ តុលាការត្រូវអនុញ្ញាតឱ្យភាគីមានឱកាសបញ្ចេញមតិ ឆ្លើយតបទៅនឹងមតិដែលថ្លែង ដោយភាគីម្ខាងទៀត មុនពេលតុលាការសម្រេចសេចក្តី។

---

[15] មាត្រា ១១៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[16] មាត្រា ៣និង ១១៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

### ២.២.១-ការសាកល្បងធ្វើការផ្សះផ្សា [17]

នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នេះ តុលាការអាចធ្វើការសាកល្បងផ្សះផ្សាភាគីសាជាថ្មីម្តង ទៀតបាន ទោះបីជាចៅក្រមបានធ្វើការផ្សះផ្សានេះ មិនបានសះជានឹងគ្នា នៅក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុ ផលក៏ដោយ។

### ២.២.២-ការធ្វើសេចក្តីថ្លែងការណ៍ [18]

នៅក្នុងនីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ ភាគីត្រូវធ្វើសេចក្តីថ្លែងការណ៍ ពីលទ្ធផលនៃនីតិវិធី ត្រៀមសម្រាប់ការទាញហេតុផល ។ ខ្លឹមសារនៃសេចក្តីថ្លែងការណ៍មានជាអាទិ៍ ការអះអាងអំពីអង្គហេតុ ដែលឆ្លើយ តបយ៉ាងជាក់លាក់ទៅនឹងការស្នើសុំឱ្យពិនិត្យភស្តុតាង និងលទ្ធផលនៃការពិនិត្យភស្តុតាងជាឯកសារ។ ក្នុងពេលធ្វើ ការទាញហេតុផលដោយផ្ទាល់មាត់នេះ ភាគី ឬមេធាវីអាចធ្វើការអះអាងបន្ថែមទៀតនូវអង្គហេតុ និងដាក់ភស្តុតាងថ្មី បន្ថែមទៀតបាន កុំអោយតែអង្គហេតុ ឬភស្តុតាងទាំងនោះ មានលក្ខណៈផ្ទុយទៅនឹងមាត្រា ១០៨ នៃក្រមនេះ។ ការរៀបចំសរសេរសេចក្តីថ្លែងការណ៍ គឺជាភារកិច្ចចាំបាច់របស់មេធាវីត្រូវតែបំពេញ ព្រោះថា វាជាមធ្យោបាយ រឺជា

សេចក្តីអះអាងដ៏ចាំបាច់ ដែលអាចធ្វើអោយតុលាការពិចារណាទាំងអង្គហេតុ និងអង្គច្បាប់។

នីតិវិធីនេះត្រូវធ្វើឡើង ដើម្បីយកសកម្មភាពដែលបានធ្វើក្នុងនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល មក ដាក់ជជែកពិភាក្សាដេញដោល ដើម្បីយកធ្វើជាមូលដ្ឋានក្នុងការចេញសាលក្រម ។

### ២.២.៣-ការអះអាងបន្ថែម ឬការដាក់មធ្យោបាយតទល់ ឬការពារថ្មី [19]

នៅពេលធ្វើការទាញយកហេតុផលដោយផ្ទាល់មាត់ ភាគី រឺមេធាវី អាចអះអាងបន្ថែមទៀត អំពីអង្គហេតុ ឬ

---

[17] មាត្រា ៩៧និង២២០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[18] មាត្រា ១១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[19] មាត្រា ១១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

ការដាក់ភស្តុតាងមកទៀតបាន។ ប៉ុន្តែបញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលអះអាងអង្គហេតុ ឬការដាក់ភស្តុតាងនោះ ផ្ទុយនឹងមាត្រា ១០៨ ក្រមនីតិវិធីរដ្ឋប្បវេណី។

ភាគី រឺមេធាវីអាចអះអាង និងដាក់ភស្តុតាងថ្មីបាន ប៉ុន្តែមិនត្រូវផ្ទុយនឹងចំណុចខាងក្រោម ៖

- ជាមធ្យោបាយដែលទាក់ទាក់ទងទៅនឹងចំណុច ដែលតុលាការត្រូវស្រាវជ្រាវដោយឆន្ទានុសិទ្ធិ
- មិនធ្វើឱ្យមានការយឺតយ៉ាវដល់នីតិវិធីបណ្តឹង ឬករណីដែលភាគីធ្វើសេចក្តីបញ្ជាក់ដំបូងថា ខ្លួនមិនអាចដាក់មធ្យោបាយនោះ មុនពេលបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោគ្មានកំហុសធ្ងន់ធ្ងរឡើយ។

ភាគីអាចស្នើសុំឱ្យតុលាការចេញដីកាសម្រេច ធ្វើនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលជាថ្មីម្តងទៀតបាន បើតុលាការយល់ឃើញថា ត្រូវការជាចាំបាច់ពិសេស ក្រោយពីបានពិនិត្យភស្តុតាងនៅក្នុងកាលបរិច្ឆេទធ្វើការទាញហេតុ ផលដោយផ្ទាល់មាត់ហើយ។

នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នេះ តុលាការនឹងធ្វើការពិនិត្យភស្តុតាងដោយសម្ងហវិធី ដែល ត្រូវសាកសួរទៅលើសាក្សី ប្រសិនបើមានការស្នើសុំ (មាត្រា ១៣៨) ការសាកសួរសាមីភាគី (មាត្រា ១៤០) ការស្នើ សុំធ្វើកោសលវិច័យ ចំណុចដែលធ្វើកោសលវិច័យ (មាត្រា ១៤៣) ការស្នើសុំឱ្យពិនិត្យភស្តុតាងជាឯកសារ (មាត្រា ១៤៨) និងការស្នើសុំត្រួតពិនិត្យ (មាត្រ ១៦១)។ មុនពេលបញ្ឈប់ការទាញហេតុផលដោយផ្ទាល់មាត់ តុលាការអាច

អនុញ្ញាតឱ្យភាគីនីមួយៗ រឺមេធាវីធ្វើការទាញហេតុផលដោយផ្ទាល់មាត់ចុងក្រោយបាន។

## ២.២.៤-ការបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ [20]

ជាធម្មតា នៅគ្រប់កាលបរិច្ឆេទនីមួយៗ នៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការបង្គាប់ឱ្យក្រឡាបញ្ជី ធ្វើកំណត់ហេតុ ហើយកំណត់ហេតុនេះ នឹងត្រូវយកទៅធ្វើជាលិខិតសាលក្រម[21]។

ប្រសិនបើយល់ឃើញថា ការវិនិច្ឆ័យអាចធ្វើទៅបានហើយ ដោយផ្អែកលើការពិនិត្យភស្តុតាង និងលទ្ធផលនៃ ការទាញយកហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ហើយចេញសាលក្រម តែម្តង។

ជាធម្មតា សាលក្រមជាសេចក្តីសម្រេចរបស់តុលាការ ដែលមានអានុភាពចងភាគីទាំងសងខាង និងតតិយជន ដែលមានការពាក់ព័ន្ធឱ្យអនុវត្តតាម ប៉ុន្តែប្រសិនបើមានភាគីណាមិនព្រមអនុវត្តសាលក្រម ភាគីម្ខាងអាចស្នើសុំទៅ តុលាការអនុវត្ត ឬអាជ្ញាសាលាឱ្យអនុវត្តបាន បើមិនដូច្នោះទេ អានុភាពនៃសាលក្រមនេះ ក៏មិនអាចកើតឡើងបាន ដែរ។

## ២.២.៥-ដំណាក់កាលក្រោយនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

មេធាវីត្រូវពន្យល់អំពីអានុភាពនៃសាលក្រម ដែលនាំឱ្យគូភាគីកើតនូវសិទ្ធិ និងកាតព្វកិច្ច។ ក្នុងដំណាក់កាល នេះ មេធាវីមានភារកិច្ចសំខាន់ៗបីយ៉ាងចំពោះកូនក្តីគឺ ៖

### ក-ការផ្តលយោបល់ឱ្យកូនក្តី

មេធាវីត្រូវផ្តល់យោបល់ដល់កូនក្តីរបស់ខ្លួន បន្ទាប់ពីតុលាការបានចេញសាលក្រម ឬសាលដីកា ។ ការផ្តល់ យោបល់នេះ មានសារៈសំខាន់ណាស់សម្រាប់កូនក្តី ទោះបីជាលទ្ធផលចាញ់ ឬឈ្នះ ព្រោះថា ជូនកាលកូនក្តីមិនមែនអ្នកមានការយល់ដឹងអំពីច្បាប់សារធាតុ និងច្បាប់ទម្រង់។ ដូច្នេះ មេធាវីត្រូវប៉ាន់ប្រមាណឱ្យបានល្អិតល្អន់ថា តើកូនក្តីរបស់ខ្លួនមានការអប់រំ និងកំរិតវប្បធម៌ដល់កំរិតណា ហើយកូនក្តីរបស់ខ្លួនអាចយល់ដឹងពីអត្ថន័យនៃសាលក្រមខ្លះៗដែរឬទេ ។ បើក្នុងករណីកូនក្តីអាចយល់ដឹងពីអត្ថន័យនៃសាលក្រមក៏ដោយ មេធាវីនៅតែមានកាតព្វកិច្ចបញ្ជាក់ឱ្យច្បាស់ ដដែល អំពីអត្ថន័យនៃ

---

[20] មាត្រា ១១៤ និង ១១៩នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

[21] មាត្រា ១១៧-១១៨ និង១១៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

សាលក្រមឱ្យកូនក្តី ព្រោះការធ្វើបែបនេះ ជាកាតព្វកិច្ចដែលមេធាវីត្រូវធ្វើពុំអាចខកខានបាន ឡើយ ហើយវាក៏ជាករណីចាំបាច់មួយ សម្រាប់មេធាវីត្រូវតែធ្វើដើម្បីជៀសវាងនូវការបាត់បង់ប្រយោជន៍ ដោយថា ហេតុរបស់កូនក្តី ដែលមិនបានធ្វើបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់។

## ខ-ពន្យល់ពីសិទ្ធិធ្វើបណ្តឹងឧបាស្រ័យរបស់កូនក្តី

បណ្តឹងឧបាស្រ័យ គឺជានីតិវិធីមួយដែលច្បាប់អនុញ្ញាតឱ្យភាគី ដែលមិនសុខចិត្តនឹងសេចក្តីសម្រេចនៅក្នុងការ ជំនុំជម្រះក្តីលើកទី ១ នៅសាលាដំបូង មានសិទ្ធិប្តឹងតវ៉ាទៅនឹងសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមនេះ ដែល ធ្វើឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ខ្លួន ។ មេធាវីត្រូវចងចាំអំពីរយៈពេលដែលច្បាប់បានកំណត់ ក្នុងការធ្វើបណ្តឹង ឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ។ មេធាវីមានកាតព្វកិច្ចពន្យល់បន្ថែមអំពីសាលក្រម ឬសាលដីកា ដែលបានសម្រេច ដោយតុលាការ។

ទោះបីជាកូនក្តីរបស់ខ្លួនជាអ្នកឈ្នះក្តី ឬជាអ្នកចាញ់ក្តីក៏ដោយ ពេលខ្លះមិនមែនសុទ្ធតែកូនក្តីដែលឈ្នះសុខ ចិត្តជាមួយនឹងសាលក្រម ឬសាលដីកា ដែលតុលាការបានសម្រេចនោះទេ ។ ហេតុនេះហើយ ច្បាប់បានបើកសិទ្ធិឱ្យអ្នក ដែលមិនសុខចិត្ត មានសិទ្ធិប្តឹងឧបាស្រ័យទៅនឹងសាលក្រម ឬសាលដីកាដែលខ្លួនមិនពេញចិត្តនោះ។ តួនាទីរបស់ មេធាវីក្នុងដំណាក់កាលនេះ គឺពន្យល់ពីប្រភេទនៃសាលក្រម ឬសាលដីកា ដែលបានសម្រេចដោយតុលាការទៅកូនក្តី របស់ខ្លួន ។

គួរបញ្ជាក់ផងដែរថា មេធាវីនៅតែដើរតួនាទីសំខាន់ដដែល ក្នុងការការពារក្តីជូនអតិថិជនរបស់ខ្លួន ដូចជា ការ ធានាពីភាពអាចទទួលយកបាននៃបណ្តឹងឧបាស្រ័យ ការរៀបចំ និងការដាក់ឯកសារត្រៀម ដែលតុលាការបង្គាប់ការ ចូលរួមនៅក្នុងសវនាការ ។ ព្រោះថា ប្រសិនបើពាក្យបណ្តឹងឧបាស្រ័យមិនបានធ្វើឡើងដោយបញ្ជាក់មូលហេតុឱ្យ បានច្បាស់លាស់នោះទេ វាអាចត្រូវបានតុលាការសម្រេចលើកចោលដោយសាលដីកា ឬដីកាសម្រេចបាន ដូច្នេះ ផល ប្រយោជន៍របស់ភាគីក៏នឹងត្រូវបាត់បង់ដែរ[22]។

[22] មាត្រា ២៦៦-២៦៨ និង២៩០ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦

## គ-ការចូលរួមអនុវត្តសាលក្រម

នៅពេលផុតរយៈពេលប្តឹងតវ៉ា តាមការកំណត់របស់ច្បាប់ហើយ ភាគីឈ្នះក្តីត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍ អក្សរ ស្នើសុំអនុវត្តដោយបង្ខំ។ តាមពាក្យសុំរបស់ភាគី ការអនុវត្តន៍ដោយបង្ខំត្រូវធ្វើឡើងដោយស្ថាប័នអនុវត្ត ដែល រួមមានតុលាការអនុវត្ត ឬអាជ្ញាសាលា។ នៅពេលដែលសាលក្រមស្ថាពរ មេធាវីអាចសុំលិខិតសាលក្រមចូលជាស្ថាពរ

នោះ ដើម្បីយកទៅអនុវត្ត។

មេធាវីត្រូវប្រាប់ទៅកូនក្តីរបស់ខ្លួន ដែលជាភាគីឈ្នះក្តី អំពីនីតិវិធីមុនពេលទទួលបានសម្រង់សាលក្រម គឺថា ត្រូវបង់ពន្ធសមាមាត្រ ជូនដល់ក្រឡាបញ្ជីមុននឹងទទួលបានសាលក្រម ប្រសិនបើរឿងក្តីនោះ ត្រូវបានតុលាការសម្រេច ឱ្យបង់ពន្ធ ។ ហើយត្រូវពន្យល់បន្ថែមទៀតថា ការបង់ពន្ធសមាមាត្រនេះ ជានិច្ចកាល អ្នកឈ្នះក្តីត្រូវតែជាអ្នកបង់មុន បន្ទាប់មកទើបបង្គាប់ឱ្យអ្នកចាញ់ក្តីសងប្រាក់នេះ ទៅអ្នកដែលបានបង់ទុករួចហើយនោះវិញ។

នៅពេលដែលអ្នកឈ្នះក្តីបានដាក់ពាក្យសុំអនុវត្តសាលក្រម ប្រធានតុលាការត្រូវពិនិត្យមើលលើពាក្យបណ្តឹង សុំនោះ ។ បើឃើញថា ពាក្យនោះមានភ្ជាប់សម្រង់សាលក្រម និងភ្ជាប់បង្កាន់ដៃបង់ពន្ធសមាមាត្រ (ប្រសិនបើក្នុង សាលក្រម មានសម្រេចបង្គាប់ឱ្យបង់ពន្ធសមាមាត្រ) មកជាមួយត្រឹមត្រូវហើយនោះ ប្រធានតុលាការចាត់ឱ្យអនុវត្ត តាមនីតិវិធី ដោយចាត់បញ្ជូនពាក្យនោះទៅព្រះរាជអាជ្ញា ដើម្បីអនុវត្ត ។

តួនាទីរបស់ព្រះរាជអាជ្ញាពេលនេះ គឺជាអ្នកដឹកនាំការអនុវត្តន៍សាលក្រម តាមការស្នើសុំរបស់ភាគី។

## ២.៣-ការទទួលខុសត្រូវរបស់មេធាវី

ក្នុងរឿងក្ដីរដ្ឋប្បវេណី វត្តមានមេធាវីមិនចាំបាច់ដូចរឿងក្ដីព្រហ្មទណ្ឌនោះទេ[23] មានន័យថា ដើមចោទ ឬចុងចំលើយអាចចូលខ្លួនមកតុលាការដោយខ្លួនឯងក៏បាន ឬក៏ផ្ទេរសិទ្ធិជូនមេធាវីឱ្យធ្វើជាអ្នកតំណាងដោយអាណត្តិជូសខ្លួនក៏បានដែរ ។ នៅក្នុងរឿងក្ដីព្រហ្មទណ្ឌ មេធាវីមិនអាចតំណាងជនជាប់ចោទបានឡើយ ប៉ុន្តែ មេធាវីអាចតំណាងឱ្យអ្នកទទួលខុសត្រូវក្នុងរឿងរដ្ឋប្បវេណី និងដើមបណ្ដឹងរដ្ឋប្បវេណី ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណីពឹងពាក់មេធាវី មេធាវីមានកាតព្វកិច្ចទទួលខុសត្រូវក្នុងរឿងរដ្ឋប្បវេណី ជាអ្នកទទួលខុសត្រូវទាមទារសំណងទាំងផ្លូវចិត្ត ផ្លូវកាយ និងខាងសម្ភារៈពីជនជាប់ចោទ ជូនជនរងគ្រោះ ឬដើមបណ្ដឹងរដ្ឋប្បវេណី ។ ដោយហេតុថា ច្បាប់ទុកសិទ្ធិឱ្យបុគ្គលម្នាក់ៗអាចជ្រើសរើសមេធាវី ដែលជាផ្នែកមួយអាចជួយជំរុញដល់ដំណើរការកាត់សេចក្ដីបានត្រឹមត្រូវយុត្តិធម៌ និងសមធម៌ដែលឱ្យគូក្ដីអាចទទួលយកបាន ម៉្យាងវិញទៀត វត្តមានមេធាវី និងរិតតែធ្វើអោយដំណើរការនីតិវិធីកាន់តែឆាប់រហ័ស។

គ្រប់ការទទួលភារកិច្ចជាអ្នកតំណាង ឬការពារជូសកូនក្ដី មិនថាក្នុងរឿងក្ដីព្រហ្មទណ្ឌ ឬក្នុងរឿងក្ដីរដ្ឋប្បវេណី មេធាវីត្រូវមើលអោយបានគ្រប់ជ្រុងជ្រោយ តាំងពីពេលចាប់ផ្ដើមចំណាត់ការបណ្ដឹង រហូតដល់ពេលបញ្ចប់សវនាការ ឬការទាញហេតុផលដោយផ្ទាល់មាត់ ដូចជា ការរៀបចំបណ្ដឹង ភស្តុតាងជាឯកសារ សេចក្ដីថ្លែងការណ៍ សំនួរដែលត្រូវឆ្លើយ ជារួមរៀបចំចំណុចសំខាន់ដែលជាផលប្រយោជន៍សំរាប់កូនក្ដីរបស់ខ្លួន។

### ២.៣.១-តក្តីភាពរបស់មេធាវីក្នុងការបំពេញបេសកកម្មជូនអតិថិជន

បើមេធាវីយល់ព្រមទទួលជួយការពារកូនក្ដីណាមួយហើយ គឺត្រូវបំពេញបេសកកម្មរបស់ខ្លួនឱ្យបានចប់សព្វគ្រប់អោយអស់ពីសមត្ថភាព និងពីចិត្តពីថ្លើម និងត្រូវការពារផលប្រយោជន៍កូនក្ដីឱ្យដូចជា ផលប្រយោជន៍របស់ខ្លួនអញ្ចឹងដែរ ។ ដោយសារហេតុផលប៉ះពាល់ដល់សម្បជញ្ញៈ មេធាវីអាចសំរេចបញ្ឈប់បេសកកម្មរបស់ខ្លួនបានតែត្រូវជូនដំណឹងទៅអតិថិជនអោយបានដឹងក្នុងរយៈពេល

[23] មាត្រា ៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦

មួយសមរម្យ ដែលអាចផ្តល់លទ្ធភាពអោយអតិថិជននោះ អាចការពារផលប្រយោជន៍របស់ខ្លួន។ មេធាវីដែលឈប់ជួយកូនក្តីដោយសារប្រការណាមួយនោះ ត្រូវប្រគល់គ្រប់ឯកសារច្បាប់ដើមទាំងឡាយណា ដែលអតិថិជនបានប្រគល់ឱ្យកន្លងមកជូនអតិថិជនវិញ[24] ហើយមេធាវីមិនអាចក្បត់កូនក្តីលួចលាក់ទុកនូវឯកសារកូនក្តី ឬបញ្ចោញព័ត៌មានសំខាន់ៗរបស់កូនក្តីឱ្យទៅភាគី គូបដិបក្សនោះបានទេ ។ ម៉្យាងវិញទៀត មេធាវីមិនត្រូវលាក់បាំងកូនក្តីនូវអ្វីដែលខ្លួនយល់ថា គួរប្រាប់ដល់កូនក្តីដើម្បីជាផលប្រយោជន៍ស្របច្បាប់របស់កូនក្តី ឬប្រើល្បិចកេងបន្លំទាញយកផលប្រយោជន៍ពីកូនក្តីនោះឡើយ ។

មេធាវីត្រូវមានសីលធម៌ខ្ពស់ក្នុងការងារ មានសេចក្តីថ្លៃថ្នូរក្នុងការប្រកបវិជ្ជាជីវៈ។ មេធាវីដែលមានអតិថិជនច្រើននាក់ពឹងពាក់ក្នុងរឿងក្តីតែមួយ ឬក្នុងប្រតិបត្តិការតែមួយ មិនត្រូវកាន់ជើងផ្តល់ប្រយោជន៍អោយតែអតិថិជនណាមួយនោះឡើយ ។ មេធាវីមិនអាចធ្វើជាអ្នកតំណាង អ្នកការពារ ឬផ្តល់យោបល់ដល់អតិថិជន ដែលមានទំនាស់ផលប្រយោជន៍នឹងគ្នាឡើយ ។ បើមេធាវីជាទីប្រឹក្សា ឬធ្លាប់ជាទីប្រឹក្សាឱ្យអតិថិជនច្រើនគ្នានោះ មេធាវីអាចនឹងទទួលការពារប្រយោជន៍ភាគីណាមួយបានលុះត្រាតែត្រូវជំរាបទៅភាគីផ្សេងទៀត ឱ្យបានដឹងជាមុនសិន និងត្រូវប្រុងប្រយ័ត្នកុំឱ្យបាត់បង់នូវភាពគួរសមសេចក្តីថ្លៃថ្នូរ និងអាថិកំបាំង វិជ្ជាជីវៈ[25]។ នៅគ្រប់រឿងក្តីទាំងអស់ មេធាវីនឹងអាចធ្វើអន្តរាគមន៍ប្រឆាំងនឹងកូនក្តី ដែលខ្លួនធ្លាប់បានជួយពីមុនបាន តែក្នុងលក្ខខណ្ឌតឹងរឹងនៃការគោរពអាថិកំបាំងវិជ្ជាជីវៈ និងភាពគួរ

សមថ្លៃថ្នូរ ហើយមេធាវីដែលជាសមាជិកនៃក្រុមប្រមូលផ្តុំមធ្យោបាយ អាចនឹងផ្តល់យោបល់ ឬតំណាងភាគីនានា ដែល

---

[24] មាត្រា ១៦ និង ១៧ នៃក្រមសីលធម៌មេធាវីឆ្នាំ ១៩៩៥

[25] មាត្រា ១៩ នៃក្រមសីលធម៌មេធាវីឆ្នាំ ១៩៩៥

មានផលប្រយោជន៍ប្រឆាំងគ្នាបាន ដរាបណាតែមានការយល់ព្រមពីអតិថិជនរៀងៗខ្លួន និងក្នុងលក្ខខណ្ឌនៃការគោរពអាថ៌កំបាំងវិជ្ជាជីវៈ[26]។ មេធាវីនៃអតិថិជនមួយ អាចទំនាក់ទំនងនឹងអតិថិជននៃភាគីគូរបដិបក្សបាន តែត្រូវមានការយល់ព្រមពីអតិថិជនខ្លួន ហើយបើអតិថិជននោះមានមេធាវី ត្រូវទទួលការអនុញ្ញាតយល់ព្រមពីមេធាវីរបស់អតិថិជននោះ មុននឹងជួប ឬត្រូវជួបនៅចំពោះមុខភាគីសាមី និងមេធាវីរបស់គេនោះ។

## ២.៣.២-ការរក្សាការសម្ងាត់វិជ្ជាជីវៈសំរាប់អតិថិជន

មេធាវីអាចលើកឡើងនូវអ្វីៗ តាមសតិសម្បជញ្ញៈរបស់ខ្លួន និងដោយមានការយល់ព្រមពីអតិថិជនផង ក្នុងគោលបំណងការពារផលប្រយោជន៍របស់អតិថិជន ដែលខ្លួនទទួលការពារនោះ ។ គ្រប់សកម្មភាពរបស់មេធាវីជាមួយអតិថិជន មេធាវីត្រូវតែរក្សាការសម្ងាត់វិជ្ជាជីវៈមេធាវីជាដាច់ខាត់ ។ វាជាគោលការណ៍គ្រឹះសំខាន់ក្នុងមុខរបរនៃវិជ្ជាជីវៈមេធាវី ដែលការសម្ងាត់នេះ មិនត្រូវអាចអោយជនណាម្នាក់ស្រង់យកបានឡើយ[27]។

ត្រូវបានចាត់ទុកថា ជាការសំងាត់នៃវិជ្ជាជីវៈផងដែរ ចំពោះការពិគ្រោះយោបល់ច្បាប់ ការផ្តល់យោបល់លើ ឯកសារក្រៅផ្លូវការទាំងឡាយ ដែលមេធាវីតាក់តែងឡើងសំរាប់អតិថិជនរបស់ខ្លួន លិខិតស្នាមទាំងឡាយ ដែល មេធាវី និងអតិថិជនផ្ញើដើម្បីធ្វើការទាក់ទងគ្នា តែមិនអាចចាត់ទុកជាការសម្ងាត់នៃវិជ្ជាជីវៈទេ បើគ្រាន់តែជានីតិវិធីតុលាការនៅក្នុងដំណើរការរឿងក្តីណាមួយនោះ[28]។ មេធាវីដែលជាអ្នកតាក់តែងលិខិតស្នាមតែម្នាក់ឯង អាចធ្វើសកម្មភាព ឬការពារលើការអនុវត្តន៍លិខិតនោះបាន នៅពេលដែលការទទួលខុសត្រូវផ្ទាល់ខ្លួនរបស់ខ្លួន ត្រូវចោទប្រកាន់ឡើង លើកលែងតែប្រឆាំងនឹងភាគីណាមួយ ដែលនៅក្នុងលិខិតស្នាមនោះ ប៉ុន្តែ បើមេធាវីដែលបានចូលរួមតាក់តែងលិខិតស្នាមក្នុងឋានៈជាទីប្រឹក្សារបស់ភាគីម្ខាងវិញ អាចធ្វើសកម្មភាព ឬការពារលើការអនុវត្តន៍លិខិត

[26] មាត្រា ២០ នៃក្រមសីលធម៌មេធាវីឆ្នាំ ១៩៩៥

[27] មាត្រា ៧ នៃក្រមសីលធម៌មេធាវីឆ្នាំ ១៩៩៥

[28] មាត្រា ២៧ នៃក្រមសីលធម៌មេធាវីឆ្នាំ ១៩៩៥

ស្នាមនោះតទល់នឹងភាគីម្ខាងទៀតបាន។ មេធាវីដែលជាអ្នកតាក់តែងលិខិតស្នាម ឬ ជាអ្នកចូលរួមតាក់តែងលិខិតស្នាម មិនអាចបំពេញ

កិច្ចការ ឬការពារលើសុពលភាព ឬ ធ្វើការបកស្រាយ លិខិតស្នាមដែលខ្លួនបានសរសេរនោះទេ កាលបើការអន្តរាគមន៍

របស់ខ្លួននាំខ្លួនអោយទៅជាសាក្សី ឬនាំអោយប៉ះពាល់ដល់អាថិកំបាំងវិជ្ជាជីវៈ[29]។

## ២.៣.៣-កំហុសចំពោះអតិថិជន

មេធាវីដែលធ្វើអោយអតិថិជនខ្លួនខាតបង់ ឬខូចប្រយោជន៍ដោយសារកំហុសរបស់ខ្លួនទោះចេតនាក្តី ឬអចេនាក្តីត្រូវទទួលខុសត្រូវចំពោះការខាតបង់របស់អតិថិជន ឬទណ្ឌកម្មផ្សេងទៀត តាមរយៈការដាក់ពាក្យបណ្តឹងពីអតិថិជនបាន ។ អតិថិជន ដែលទទួលរងការខាតបង់ប្រយោជន៍ ដោយសារកំហុសរបស់មេធាវី គឺត្រូវតែបង្ហាញអោយឃើញពីកំហុសបេស់មេធាវីដែលនាំអោយខ្លួនខូចផលប្រយោជន៍ មានការខូចខាតពិតប្រាកដ មានកំហុស និងការខូចផលប្រយោជន៍មានចំណងទាក់ទងគ្នា ។ បណ្តឹងអំពីកំហុសមេធាវី ឬអំពីបទព្រហ្មទណ្ឌ ដែលទាក់ទិងនឹងការប្រកបវិជ្ជាជីវៈ ត្រូវជូនដំណឹងភ្លាមទៅប្រធានគណៈមេធាវី[30]។

កំហុសចំពោះអតិថិជនរួមមានៈ

- ការប្រើល្បិចកេងបន្លំ ដើម្បីទាញយកផលប្រយោជន៍អតិថិជន
- ការទំនាក់ទំនងជាមួយអតិថិជនម្ខាងទៀត ដែលជាគូបដិបក្ខ ដោយពុំមានការយល់ព្រមពីអតិថិជនខ្លួន។
- ការលាក់ទុកនូវឯកសារទាំងឡាយរបស់អតិថិជន ឬទំលាយការសំងាត់ប្រាប់ទៅដល់អតិថិជនម្ខាងទៀត។

---

[29] មាត្រា ៨ នៃក្រមសីលធម៌មេធាវីឆ្នាំ ១៩៩៥

[30] មាត្រា ៣៧ នៃក្រមសីលធម៌មេធាវីឆ្នាំ ១៩៩៥

- ការផ្ដល់យោបល់ ឬតំណាង ឬការពារភាគីច្រើនគ្នា តែកាន់យើង ឬផ្ដល់ប្រយោជន៍ដល់បុគ្គលណាម្នាក់។
- ការធ្វើអន្តរាគមន៍ ប្រឆាំងនឹងកូនក្ដីរបស់ខ្លួន ដែលជួយការពារពីលើកមុនផង និងការពារ ឬផ្ដល់យោបល់ ឬតំណាងឱ្យភាគីមួយទៀត ដែលជាគូបដិបក្ខ ក្នុងរឿងក្ដីតែមួយ ។
- ការលាក់លៀមចំពោះកូនក្ដី នូវអ្វីដែលជាប្រយោជន៍របស់កូនក្ដី
- ការធ្វើអន្តរាគមន៍ ការពារផលប្រយោជន៍អោយកូនក្ដីប្រឆាំងនឹងក្រសួងមន្ទីររបស់ខ្លួន ដែលមេធាវីធ្លាប់ជាអតីតមន្ត្រីរាជការនៅក្រោមឱវាទ លុះត្រាតែផុតរយៈពេល ៥ ឆ្នាំ គិតចាប់ពីថ្ងៃដែលខ្លួនលាលែងឈប់ពីមុខងារពី

  ក្រសួង ឬមន្ទីរនោះ[31]។

[31] មាត្រា ៥៥ នៃក្រមសីលធម៌មេធាវីឆ្នាំ ១៩៩៥